ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋាន

លេខ: ២៧/២០១៧ អ.កបធ.សជណ

# សេចក្ដីប្រកាសព័ត៌មាន

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ មានកិត្តិយសសូមជម្រាបជូនសាធារណជនជ្រាបថា នៅថ្ងៃពុធ **ទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧** វេលាម៉ោង ១០:០០ព្រឹក នៅសាលប្រជុំអគារ «ស» វិមានរដ្ឋចំការមន ក្រុមប្រឹក្សាធម្មនុញ្ញបានបើកកិច្ចប្រជុំពេញអង្គ ដើម្បីពិនិត្យ និងសម្រេចលើសំណុំរឿង ៖

១-លេខ៣២២/០៦០/២០១៧ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ហើយបានចេញសេចក្ដីសម្រេចលេខ១៧៩/០១៩/២០១៧ កបធ.ច ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ដោយបានតម្កល់សេចក្ដីសម្រេចលេខ១១០ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល។

២-លេខ៣២៤/០៦២/២០១៧ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ហើយបានចេញសេចក្ដីសម្រេចលេខ១៨០/០២០/២០១៧ កបធ.ច ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ដោយបានតម្កល់សេចក្ដីសម្រេចលេខ១១៣ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការ តែបដិសេធចោលការរក្សាឈ្មោះ **តួច សុផល** ភេទស្រី កើតថ្ងៃទី០២ ខែមីនា ឆ្នាំ១៩៥៣ ដែលពុំមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ដំបូងឆ្នាំ២០១៦ នៃសង្កាត់អូរឬស្សីទី៤ និង ដកឈ្មោះ **ទ្រី ឆេងហុង** ភេទប្រុស កើតថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៦ និងឈ្មោះ **មួន ដាណេ** ភេទស្រី កើតថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៧៦ ចេញពីបញ្ជីបណ្ដឹងនៃការិយាល័យលេខ ០៣៨៤ នៃសង្កាត់អូរឬស្សីទី៤ តាមសំណូមពររបស់ដើមបណ្ដឹង។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើសូមសាធារណជនជ្រាប។

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ / ទូរសារ: (៨៥៥) ២៣ ៧២៦ ០៣១, E-mail: sgccc@online.com.kh / info@ccc.gov.kh, Website :http://www.ccc.gov.kh,ប្រអប់សំបុត្រ ២៤៨៣ ភ្នំពេញ